គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ២៧ ចេញផ្សាយថ្ងៃទី៣ ខែមករា ឆ្នាំ២០២២
No. 27 Released on January 3, 2022

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## ការផ្តន្ទាទោសពិន័យជាប្រាក់ចំពោះបរធនបាលដែលប្រព្រឹត្តល្មើស (ត)

## Punishment in A Financial Fine for Trustees Who Commit Crimes (Continued)

យោងតាមមាត្រា៤៨ និង៤៩ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាលដែលទម្លាយការសម្ងាត់វិជ្ជាជីវៈដែលបណ្តាលឱ្យខូចផលប្រយោជន៍ភាគីពាក់ព័ន្ធ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល និង/ ឬដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ។ នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២នៃច្បាប់នេះ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៤៣ កថាខណ្ឌទី២នៃមាត្រា៤៤ និងចំណុចទី១ ទី៤ និងទី៥នៃមាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៨នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន) រៀល ទៅ ២០០ ០០០ ០០០ (ពីររយលានរៀល) និងមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ ស្តីពីទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ (*ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)*។

**ឯកសារយោង | References**:

- មាត្រា៤៨&៤៩, ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

According to article 48 and 49 of the Law on Trust (2019) a trustee who breaches professional confidentiality causing damage to interest of the related parties shall be punished in a financial fine from 50,000,000 (fifty million) riels to 100,000,000 (one hundred million) riels and /or be imprisoned from 1 (one) month to 1 (one) year. A legal entity/person may be declared as criminal responsibility in accordance with the conditions as stated in article 42 on criminal responsibility of the legal entity of the penal code for offences as stated in the 2nd paragraph of the article 43, the 2nd paragraph of the article 44 and the point No.1, point No. 4 and the point No. 5 of the article 45, article 46 and article 48 of this law. A legal entity shall be penalized in a financial fine from 50,000,000 (fifty million) riels to 200,000,000 (two hundred million) riels and shall not allow to act as a trustee in the Kingdom of Cambodia as well as any additional penalties or more as stated in the article 168 on additional penalties applicable to legal entities of the penal code (*Law on Trust, 2019; Law on the Organization and Functioning of the Non-Bank Financial Services Authority (NBFSA), 2021; Sub-Decree on the Organization and Functioning of Units Under the NBFSA, 2021*).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh